ទីស្តីការគណៈរដ្ឋមន្ត្រី
អគ្គនាយកអ្នកនាំពាក្យរាជរដ្ឋាភិបាល
លេខៈ ...... អអរ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សេចក្តីប្រកាសព័ត៌មាន
ស្តីពី
លទ្ធផលនៃដំណើរទស្សនកិច្ចផ្លូវការរបស់ ឯកឧត្តម ឡេ មិញ ហ៊ឹង នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋសង្គមនិយមវៀតណាម នៅព្រះរាជាណាចក្រកម្ពុជា

ឯកឧត្តម **ឡេ មិញ ហ៊ឹង** នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងគណៈប្រតិភូរដ្ឋាភិបាលវៀតណាម បានអញ្ជើញធ្វើមាតុភូមិនិវត្តន៍ទៅកាន់ប្រទេសវៀតណាមវិញ នៅរសៀលថ្ងៃសៅរ៍ ទី១០ ខែតុលា ឆ្នាំ២០២៦ នេះ បន្ទាប់ពីបានបំពេញទស្សនកិច្ចផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា រយៈពេល ២ថ្ងៃ ចាប់ពីថ្ងៃទី៩ ដល់ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៦ តបតាមការអញ្ជើញរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងអំឡុងពេលបំពេញទស្សនកិច្ចផ្លូវការនេះ ឯកឧត្តមនាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងគណៈប្រតិភូ បានអញ្ជើញចូលក្រាបថ្វាយបង្គំគាល់ ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ នៃព្រះរាជាណាចក្រកម្ពុជា នៅព្រះបរមរាជវាំង និងជំនួបសម្តែងការគួរសមជាមួយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និង **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភា ព្រមទាំងជំនួបទ្វេភាគីជាមួយ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

ជំនួបទ្វេភាគី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងថ្នាក់ដឹកនាំរាជរដ្ឋាភិបាលកម្ពុជា ទទួលស្វាគមន៍យ៉ាងកក់ក្តៅ និងអញ្ជើញធ្វើបដិសណ្ឋារកិច្ចផ្លូវការប្រកបដោយកិត្តិយសជូន ឯកឧត្តម **ឡេ មិញ ហ៊ឹង** នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងគណៈប្រតិភូ នៅវិមានសន្តិភាព។ នៅក្នុងជំនួបទ្វេភាគីនេះ **សម្តេចធិបតី** បានគូសបញ្ជាក់ថា វត្តមានរបស់ ឯកឧត្តមនាយករដ្ឋមន្ត្រីវៀតណាម ជាការបញ្ជាក់ពីការយកចិត្តទុកដាក់ក្នុងការពង្រឹងទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការនៃប្រទេសទាំងពីរឱ្យកាន់តែរឹងមាំបន្ថែមទៀត។ **សម្តេចធិបតី** បានកោតសរសើរ និងអបអរសាទរដល់សាធារណរដ្ឋសង្គមនិយមវៀតណាម ចំពោះការសម្រេចបាននូវកំណើនសេដ្ឋកិច្ចក្នុងអត្រា ៨.០២% ក្នុងឆ្នាំ២០២៤ និងអត្រា ៩.០១% ក្នុងរយៈពេល ៩ខែ ដើមឆ្នាំ២០២៦ ព្រមទាំងបានបង្ហាញនូវជំនឿជាក់យ៉ាងមុតមាំថា

ទីស្តីការគណៈរដ្ឋមន្ត្រី លេខ៨១ មហាវិថីសហព័ន្ធរុស្សី (១១០), រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Website : rgsu.gov.kh / Facebook page : Royal Government Spokesperson Unit / Telegram : https : // t. me / Cambodia Government Spokesperson

ក្រោមការដឹកនាំរបស់បក្សនិងរដ្ឋ វៀតណាមនឹងសម្រេចបាននូវកំណើនក្នុងរង្វង់២ខ្ទង់ ឈានទៅសម្រេចទិសដៅសហស្សវត្សរ៍ទាំងពីរនៅឆ្នាំ២០៣០ និងឆ្នាំ២០៤៥។ **សម្តេចធិបតី** ក៏បានជម្រាបជូន **ឯកឧត្តមនាយករដ្ឋមន្ត្រី** អំពីការវិវត្តថ្មីៗនៃស្ថានការណ៍ជម្លោះព្រំដែនកម្ពុជា-ថៃ ព្រមទាំងបានសង្កត់ធ្ងន់អំពីការប្តេជ្ញាចិត្តនិងជំហររបស់កម្ពុជាក្នុងការប្រកាន់យកការដោះស្រាយបញ្ហាព្រំដែនដោយសន្តិវិធី ផ្អែកលើច្បាប់អន្តរជាតិ និងអនុលោមតាមអនុសញ្ញា សន្ធិសញ្ញា និងកិច្ចព្រមព្រៀងរវាងកម្ពុជា-ថៃ។ ជាការឆ្លើយតប **ឯកឧត្តមនាយករដ្ឋមន្ត្រីវៀតណាម** បានគូសបញ្ជាក់ថា ដំណើរទស្សនកិច្ចផ្លូវការនេះ នឹងបន្តជំរុញទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការទ្វេភាគីឱ្យកាន់តែរឹងមាំនិងស៊ីជម្រៅ ក៏ដូចជាជំរុញការអនុវត្តកិច្ចសហប្រតិបត្តិការជាក់ស្តែងរវាងប្រទេសទាំងពីរឱ្យកាន់តែរីកចម្រើនថែមទៀត។

ប្រមុខរដ្ឋាភិបាលទាំងពីរ បានសម្តែងនូវការពេញចិត្តចំពោះភាពរីកចម្រើននៃទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការទ្វេភាគីលើគ្រប់វិស័យ ព្រមទាំងបានគូសបញ្ជាក់ថា ឆ្នាំ២០២៧ ខាងមុខ ជាខួបលើកទី៦០ នៃការបង្កើតទំនាក់ទំនងការទូត ក៏ដូចជាឆ្នាំមិត្តភាពរវាងប្រទេសទាំងពីរ។ **ប្រមុខរដ្ឋាភិបាលទាំងពីរ** បានឯកភាពគ្នាក្នុងការជំរុញឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធ ក៏ដូចជាយុវជននៃប្រទេសទាំងពីរៀបចំព្រឹត្តិការណ៍នានាដើម្បីអបអរសាទរខួបនៃការបង្កើតទំនាក់ទំនងការទូត និងឆ្នាំមិត្តភាពនៃប្រទេសទាំងពីរ។ **ប្រមុខរដ្ឋាភិបាលទាំងពីរ** ក៏បានឯកភាពគ្នាក្នុងការជំរុញទំនាក់ទំនងទ្វេភាគីឱ្យឈានដល់កម្រិតថ្មីមួយទៀត ក៏ដូចជាការជំរុញពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការឱ្យកាន់តែស៊ីជម្រៅ ព្រមទាំងបានបន្តពិភាក្សា និងផ្លាស់ប្តូរយោបល់អំពីការជំរុញកិច្ចសហប្រតិបត្តិការលើវិស័យសំខាន់ៗ រួមមាន នយោបាយ ការពារជាតិនិងសន្តិសុខ សេដ្ឋកិច្ចពាណិជ្ជកម្មនិងវិនិយោគ កសិកម្ម ថាមពល អប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ ការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធ ទេសចរណ៍ ការតភ្ជាប់រវាងប្រជាជននិងប្រជាជន ក៏ដូចជាការជំរុញការផ្លាស់ប្តូរទស្សនកិច្ចរវាងយុវជននិងយុវជន និងរវាងបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាម។

ក្នុងឱកាសនោះ **ប្រមុខរដ្ឋាភិបាលទាំងពីរ** បានអញ្ជើញជាសហអធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ចំនួន ៦ឯកសារ រួមមាន ១. អនុស្សរណៈនៃការយោគយល់គ្នារវាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀននៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងសន្តិសុខសាធារណៈនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការសាងសង់មជ្ឈមណ្ឌលជាតិព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ស្វាយរៀង។ ២. កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យអប់រំសម្រាប់រយៈពេល ២០២៦-២០៣០។ ៣. អនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអភិរក្ស និងការផ្សព្វផ្សាយស្តុបមិត្តភាពកម្ពុជា-វៀតណាម នៅព្រះរាជាណាចក្រកម្ពុជារវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម។ ៤. អនុស្សរណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការសន្តិសុខរវាងមជ្ឈមណ្ឌលជាតិបច្ចេកវិទ្យាព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងសន្តិសុខសាធារណៈនៃសាធារណរដ្ឋសង្គមនិយមវៀតណាម។ ៥. អនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការបង្កើតគណៈកម្មាធិការពាណិជ្ជកម្មចម្រុះរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម។ និង ៦. កិច្ចសម្របសម្រួលជំរុញពាណិជ្ជកម្មទ្វេភាគីរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

ក្នុងវេទិកាធុរកិច្ចកម្ពុជា-វៀតណាម ឆ្នាំ២០២៦ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានអញ្ជើញថ្លែងសុន្ទរកថា គន្លឹះថា វត្តមានដ៏ច្រើនកុះកររបស់ធុរជនកម្ពុជា និងវៀតណាមនាថ្ងៃនេះ បានឆ្លុះបញ្ចាំងពីទំនុកចិត្ត និងចំណាប់អារម្មណ៍របស់វិស័យឯកជនក្នុងការពង្រីកកិច្ចសហប្រតិបត្តិការផ្នែកពាណិជ្ជកម្ម វិនិយោគ និងធុរកិច្ចរវាងប្រទេសទាំងពីរ។ វេទិកានាថ្ងៃនេះ ប្រព្រឹត្តទៅក្នុងពេលដែលសភាពការណ៍តំបន់ និងសកលមានការប្រែប្រួលយ៉ាងឆាប់និងស្មុគស្មាញ ដែលការណ៍នេះកំពុងជំរុញឱ្យមានការរៀបចំឡើងវិញនូវខ្សែច្រវាក់ផ្គត់ផ្គង់ និងការផ្លាស់ប្តូរវិធាននៃការសម្រេចចិត្តក្នុងការវិនិយោគ។ ក្នុងបរិការណ៍នេះ អ្វីដែលគួរឱ្យកត់សម្គាល់នោះគឺ កម្ពុជា និងវៀតណាមបន្តជ្រើសរើសយកការតភ្ជាប់កិច្ចសហប្រតិបត្តិការ និងការបំពេញឱ្យគ្នាទៅវិញទៅមក។ ទំនាក់ទំនងរវាងប្រទេសទាំងពីរ មិនត្រឹមតែបន្តរក្សាបាននូវភាពរឹងមាំ និងស្ថិរភាពប៉ុណ្ណោះទេ ប៉ុន្តែកំពុងមានសម្ទុះកាន់តែខ្លាំងទាំងក្នុងទំនាក់ទំនងពាណិជ្ជកម្ម វិនិយោគ ទេសចរណ៍ ការតភ្ជាប់ និងការផ្លាស់ប្តូររវាងប្រជាជននិងប្រជាជន។ ជាក់ស្តែង ក្នុងឆ្នាំ២០២៦នេះ មានការផ្លាស់ប្តូរទស្សនកិច្ច និងជំនួបជាន់ខ្ពស់ជាបន្តបន្ទាប់នៃប្រទេសទាំងពីរ ដោយបានឆ្លុះបញ្ចាំងពីទំនុកចិត្តនយោបាយដ៏រឹងមាំ និងឆន្ទៈរួមក្នុងការបន្តពង្រឹងទំនាក់ទំនងភាពជាអ្នកជិតខាងល្អ មិត្តភាពជាប្រពៃណី កិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយ និងស្ថិរភាពយូរអង្វែង ព្រមទាំងជំរុញទំនាក់ទំនងសេដ្ឋកិច្ចរវាងប្រទេសទាំងពីរឱ្យឈានដល់កម្រិតថ្មីមួយទៀត។ កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរវាងកម្ពុជានិងវៀតណាម ក៏បានបន្តរីកចម្រើនគួរឱ្យកត់សម្គាល់។ ប្រទេសទាំងពីរក៏បានដាក់ចេញនូវមហិច្ឆតារួម ក្នុងការជំរុញទំហំពាណិជ្ជកម្មទ្វេភាគីឱ្យឈានដល់ ២០ប៊ីលានដុល្លារអាម៉េរិក នាពេលខាងមុខ។ ទន្ទឹមនេះ គិតចាប់ពីឆ្នាំ១៩៩៤ ដល់ខែកញ្ញា ឆ្នាំ២០២៦ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានចុះបញ្ជីគម្រោងវិនិយោគវៀតណាមសរុបចំនួន ១០៧គម្រោង ក្នុងទំហំទុនវិនិយោគប្រមាណ ៣,៦ប៊ីលានដុល្លារអាម៉េរិក។ **សម្តេចធិបតី** បានវាយតម្លៃខ្ពស់ចំពោះការរួមចំណែករបស់វិនិយោគិនវៀតណាម ក្នុងដំណើរអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា អស់រយៈពេលជាង ៣ទសវត្សរ៍កន្លងមកនេះ។ ជាមួយគ្នានេះ កម្ពុជានិងវៀតណាមបាននិងកំពុងធ្វើការរួមគ្នាតភ្ជាប់ផ្លូវល្បឿនលឿនភ្នំពេញ-បាវិត ជាមួយផ្លូវល្បឿនលឿនម៉ុកបៃ-ហូជីមិញ និងពន្លឿនការដាក់បញ្ចូលច្រកទ្វារអន្តរជាតិម៉ឺនជ័យ-តឺនណាម ទៅក្នុងកិច្ចព្រមព្រៀងស្តីពីទំនិញឆ្លងកាត់ និងកិច្ចព្រមព្រៀងស្តីពីការដឹកជញ្ជូនតាមផ្លូវគោក ដើម្បីសម្រួលដល់ការដឹកជញ្ជូនឆ្លងកាត់ព្រំដែន។

ក្នុងឆ្នាំ២០២៥ កម្ពុជាបានទទួលភ្ញៀវទេសចរវៀតណាម ប្រមាណជាង ១លាននាក់ ដែលធ្វើឱ្យវៀតណាមក្លាយជាទីផ្សារទេសចរណ៍ធំជាងគេរបស់កម្ពុជា។ ទន្ទឹមគ្នានេះ ប្រជាជនកម្ពុជាកាន់តែច្រើនក៏កំពុងជ្រើសរើសវៀតណាមជាគោលដៅសម្រាប់ទេសចរណ៍ និងសេវាសុខភាព ផងដែរ។ ក្នុងឆ្នាំ២០២៥ ភ្ញៀវទេសចរពីកម្ពុជាទៅវៀតណាម បានកើនឡើងប្រមាណ ៤៥% បើធៀបនឹងឆ្នាំ២០២៤។ **សម្តេចធិបតី** បានមានប្រសាសន៍ថា ប្រទេសទាំងពីរមានព្រំដែនជាប់គ្នា និងវិស័យជាច្រើនដែលអាចបំពេញឱ្យគ្នាទៅវិញទៅមក ដូច្នេះត្រូវបន្តពង្រឹងការតភ្ជាប់ សម្រួលការវិនិយោគ ធុរកិច្ច និងពាណិជ្ជកម្ម និងបង្កើតលក្ខខណ្ឌកាន់តែអំណោយផល ដើម្បីឱ្យវិស័យឯកជននៃប្រទេសទាំងពីរ អាចធ្វើការជាមួយគ្នាបានកាន់តែងាយស្រួល និងបង្កើតតម្លៃបន្ថែមកាន់តែច្រើន។

ក្នុងដំណើរបំពេញទស្សនកិច្ចផ្លូវការនេះ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានអញ្ជើញរៀបចំពិធីជប់លៀងផ្លូវការជូន **ឯកឧត្តមនាយករដ្ឋមន្ត្រី** និងគណៈប្រតិភូរដ្ឋាភិបាលវៀតណាម នៅវិមានសន្តិភាព។

ជំនួបសម្តែងការគួរសម

នៅវិមានសាមគ្គីភាព **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅជូនចំពោះ **ឯកឧត្តម ឡេ មិញ ហ៊ឹង** នាយករដ្ឋមន្ត្រី

នៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងគណៈប្រតិភូ ដែលបានអញ្ជើញមកបំពេញទស្សនកិច្ចផ្លូវការ នៅព្រះរាជាណាចក្រកម្ពុជា នាពេលនេះ។ **សម្តេចប្រធានព្រឹទ្ធសភា** បានចាត់ទុកដំណើរទស្សនកិច្ចរបស់ **ឯកឧត្តមនាយករដ្ឋមន្ត្រីវៀតណាម** មកកាន់កម្ពុជានៅពេលនេះ នឹងញ៉ាំងឱ្យទំនាក់ទំនងរវាងកម្ពុជានិងវៀតណាម កាន់តែរឹងមាំបន្ថែមទៀត តាមរយៈវិស័យសេដ្ឋកិច្ច និងការវិនិយោគ ដែលជាចំណុចស្នូលនៃទំនាក់ទំនងរវាងកម្ពុជានិងវៀតណាម ដោយ **សម្តេចតេជោ** ជំរុញឱ្យរដ្ឋាភិបាលនៃប្រទេសទាំងពីរខិតខំប្រឹងប្រែងយកចិត្តទុកដាក់ក្នុងការជំរុញពាណិជ្ជកម្មរវាងកម្ពុជានិងវៀតណាម ឱ្យមានការកើនឡើងបន្ថែមទៀត។ ក្នុងឱកាសនោះ **ឯកឧត្តមនាយករដ្ឋមន្ត្រី** បានលើកឡើងថា **សម្តេចតេជោ** គឺជាមិត្តដ៏ជិតស្និទ្ធបំផុតរបស់វៀតណាម។ ទន្ទឹមនេះ **ឯកឧត្តម** បានកោតសរសើរពីភាពរីកចម្រើននៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ ដោយមានការអភិវឌ្ឍជាបន្តបន្ទាប់។ **ឯកឧត្តមនាយករដ្ឋមន្ត្រី** ក៏បានអបអរសាទរចំពោះកម្ពុជាដែលបានរៀបចំសន្និសីទប្រធានសភានៃអន្តរសភាបានយ៉ាងជោគជ័យ កាលពីពេលកន្លងទៅ។ បន្ថែមលើនេះ **ឯកឧត្តមនាយករដ្ឋមន្ត្រី** បានលើកឡើងអំពីការផ្តោតសំខាន់ទៅលើពាណិជ្ជកម្មនៅតាមព្រំដែនរវាងកម្ពុជានិងវៀតណាម ឱ្យមានភាពមមាញឹកថែមទៀត ដើម្បីជំរុញសេដ្ឋកិច្ចឱ្យកាន់តែរីកចម្រើនរវាងប្រទេសទាំងពីរ។

នៅវិមានរដ្ឋសភា **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា បានគាំទ្រពេញទំហឹងចំពោះកិច្ចសហប្រតិបត្តិការកាន់តែជិតស្និទ្ធនិងរឹងមាំរវាងរដ្ឋាភិបាលកម្ពុជានិងវៀតណាម ក្នុងការបម្រើផលប្រយោជន៍ប្រជាពលរដ្ឋនៃប្រទេសទាំងពីរ ជាពិសេស អនុស្សរណៈនៃការយោគយល់គ្នា ចំនួន ៦ ដែលបានចុះហត្ថលេខារួចពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្ម សេដ្ឋកិច្ច ការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធ សុខាភិបាល សន្តិសុខ និងអប់រំ ជាដើម សំដៅជំរុញទំហំពាណិជ្ជកម្មទ្វេភាគីសម្រេចបានចំនួន ២០ពាន់លានដុល្លារអាម៉េរិក នាពេលដ៏ខ្លីខាងមុខនេះ។ ក្នុងឱកាសនោះ **ឯកឧត្តមនាយករដ្ឋមន្ត្រី** បានកោតសរសើរនិងវាយតម្លៃខ្ពស់ពីការរីកចម្រើនឥតឈប់ឈរបស់កម្ពុជាក្រោមការដឹកនាំរបស់ **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី**។ **ឯកឧត្តម** មានជំនឿមុតមាំថា ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល ព្រឹទ្ធសភា រដ្ឋសភា នៅក្រោមម្លប់ដ៏ត្រជាក់នៃអង្គព្រះមហាក្សត្រកម្ពុជា នឹងសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ឆ្នាំ២០៥០ ជាមិនខានឡើយ។

ក្នុងឱកាសនៃដំណើរបំពេញទស្សនកិច្ចផ្លូវការនេះ **ឯកឧត្តម ឡេ មិញ ហឺង** នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងគណៈប្រតិភូ បានអញ្ជើញដាក់កម្រងផ្កាថ្វាយព្រះវិញ្ញាណក្ខន្ធ នៅមណ្ឌបព្រះបរមរូប ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** "ព្រះបរមរតនកោដ្ឋ" អតីតព្រះមហាវីរក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងអញ្ជើញដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធនៅវិមានឯករាជ្យ និងនៅស្តូបមិត្តភាពកម្ពុជា-វៀតណាម៕

ថ្ងៃសៅរ៍ ១៤រោច ខែភទ្របទ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៦